**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ០៥ សរ

## សារលិខិត
## សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
## ក្នុងឱកាសអបអរសាទរទិវាវប្បធម៌ជាតិ លើកទី២៤ ឆ្នាំ២០២២

*បងប្អូនជនរួមជាតិទាំងអស់ជាទីស្រឡាញ់រាប់អាន!*

ថ្ងៃនេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជានិងខ្លួនខ្ញុំផ្ទាល់ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំមានសេចក្ដីសោមនស្សរីករាយសូមផ្ញើសារលិខិតមួយនេះ ជូនដល់បងប្អូនជនរួមជាតិទាំងអស់ ពិសេសសិល្បករ សិល្បការិនី ក្មួយៗជាយុវជន និងអ្នកស្រឡាញ់សិល្បៈវប្បធម៌ខ្មែរនៅគ្រប់ទិសទីទាំងអស់ក្នុងពិភពលោក ក្នុងឱកាសប្រារព្ធទិវាវប្បធម៌ជាតិ លើកទី២៤ ឆ្នាំ២០២២ ក្រោមប្រធានបទ **"យុវជនដើម្បីវប្បធម៌ជាតិ"**។ ទន្ទឹមនឹងសារលិខិតមួយនេះ ខ្ញុំក៏បានចេញសារាចរជាចំដោយឡែកផ្សេងមួយទៀត ដើម្បីណែនាំដល់គ្រប់ក្រសួងស្ថាប័ន និងភាគីពាក់ព័ន្ធទាំងអស់ឱ្យចូលរួមរៀបចំកម្មវិធីអបអរសាទរទិវាវប្បធម៌ជាតិ លើកទី២៤ ឆ្នាំ២០២២នេះ ឱ្យប្រព្រឹត្តទៅដោយរលូន ស្របតាមគន្លងប្រក្រតីភាពថ្មីផងដែរ។ តាមរយៈសារាចរនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាគ្រប់ក្រសួងស្ថាប័ននិងអង្គភាពពាក់ព័ន្ធទាំងអស់ នឹងចូលរួមសហការរៀបចំតាមលទ្ធភាពគ្រប់ៗគ្នា ដើម្បីប្រារព្ធទិវាវប្បធម៌ជាតិ លើកទី២៤នេះ ឱ្យបានព្រមៗគ្នានៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០២២នេះ។

ទោះបីក្នុងឆ្នាំ២០២២នេះ ទិវាវប្បធម៌ជាតិ ត្រូវបន្តរៀបចំទៅតាមគន្លងប្រក្រតីភាពបែបថ្មីក៏ដោយ ប៉ុន្តែនេះគឺជាស្មារតីយកចិត្តទុកដាក់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជាទាំងចំពោះវប្បធម៌ជាតិនិងចំពោះសុខភាពសាធារណៈ ពិសេសនៅក្នុងកាលៈទេសៈដែលវីរុសកូវីដ-១៩ បំប្លែងខ្លួនថ្មីអូមីក្រុង បាននិងកំពុងរីករាលដាលឆ្លងខ្លាំងគួរឱ្យកត់សម្គាល់នៅក្នុងសហគមន៍របស់យើង។ ឆ្លៀតក្នុងឱកាសនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមរំលឹកថារាជរដ្ឋាភិបាលកម្ពុជា បានប្រារព្ធទិវាវប្បធម៌ជាតិ ចំនួន ២៣លើក រួចមកហើយ ដោយក្នុងនោះរាជរដ្ឋាភិបាលដែលមានក្រសួងវប្បធម៌និងវិចិត្រសិល្បៈជាសេនាធិការ តែងតែរៀបចំព្រឹត្តិការណ៍ និងកម្មវិធីផ្សព្វផ្សាយអំពីសិល្បៈវប្បធម៌ជាច្រើនដើម្បីអបអរសាទរនៅក្នុងឱកាសប្រារព្ធទិវាវប្បធម៌ជាតិជារៀងរាល់ឆ្នាំ។ ពីមួយឆ្នាំទៅមួយឆ្នាំ កម្មវិធីអបអរសាទរទិវាវប្បធម៌ជាតិ ត្រូវបានរៀបចំកាន់តែអធិកអធមឡើងៗ ដោយចាប់ពីឆ្នាំ២០១៨មក យើងបានរៀបចំឱ្យមានពិធីជួបជុំនិងទទួលទានអាហារសាមគ្គីដ៏ធំរវាងប្រមុខរាជរដ្ឋាភិបាលកម្ពុជា ជាមួយ

អ្នកសិល្បៈវប្បធម៌ពីគ្រប់មណ្ឌលដ្ឋានប្រមាណ៤០០០នាក់។ ដោយឡែក ចំពោះកម្មវិធីអបអរសាទរទិវាវប្បធម៌ជាតិ លើកទី២៣ ក្នុងឆ្នាំ២០២១កន្លងទៅ រាជរដ្ឋាភិបាលបានផ្អាកពលកម្មវិធីទាំងឡាយណាដែលមានការជួបជុំមនុស្សដោយផ្ទាល់ច្រើន និងសម្រេចរក្សាទុកត្រឹមការរៀបចំសារាចរ គំនូរផ្សាយ ឯកសារ វីដេអូ និងបដាអបអរសាទរជាដើម ដើម្បីទប់ស្កាត់ការរីករាលដាលឆ្លងជំងឺកូវីដ-១៩ ពិសេសព្រឹត្តិការណ៍ "២០ កុម្ភៈ"។

*បងប្អូនជនរួមជាតិទាំងអស់ជាទីស្រឡាញ់រាប់អាន!*

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំតែងតែយកចិត្តទុកដាក់ខ្ពស់ជាប់ជានិច្ចចំពោះការងារវប្បធម៌ដែលជាផ្លូវព្រលឹង ជាអត្តសញ្ញាណ ជាកិត្យានុភាព និងជាមោទនភាពរបស់ជាតិ។ ទោះបីរងការខាតពីការរីករាលដាលឆ្លងនៃជំងឺកូវីដ-១៩ជាបន្តបន្ទាប់យ៉ាងណាក្តី រាជរដ្ឋាភិបាលកម្ពុជានៅតែបន្តយកចិត្តទុកដាក់ខ្ពស់ចំពោះវិស័យវប្បធម៌ជានិច្ច ដោយក្នុងនោះទិវាវប្បធម៌ជាតិមិនដែលត្រូវបានអាក់ខានក្នុងការរៀបចំម្តងណាឡើយ។ បើមិនមានជំងឺកូវីដ-១៩ទេ សមពេលនេះ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងរៀបចំកម្មវិធីអបអរសាទរយ៉ាងអធិកអធម ឱ្យសក្តិសមជាមួយនឹងគុណូបការៈដ៏ធំធេងរបស់បុព្វបុរសខ្មែរដែលបានបន្សល់ទុកនូវស្នាដៃអច្ឆរិយៈដ៏មហាស្ចារ្យសម្រាប់ប្រជាជាតិខ្មែរ និងសមស្របទៅតាមការអភិវឌ្ឍរីកចម្រើនរបស់ប្រទេសកម្ពុជានាពេលបច្ចុប្បន្នជាក់ជាមិនខាន។ ទោះបីឆ្នាំ២០២១គឺជាពេលវេលាដ៏លំបាកជាងគេ ដោយសារការបិទខ្ទប់ប្រទេសនិងភូមិសាស្ត្រសំខាន់ៗស្ទើរពេញមួយឆ្នាំពេញក៏ដោយ ប៉ុន្តែរាជរដ្ឋាភិបាលនៅតែបន្តរក្សាកញ្ចប់ថវិកាសម្រាប់ជួសជុលនិងថែទាំប្រាសាទក្នុងតំបន់បេតិកភណ្ឌពិភពលោកដដែល ដោយមិនបានធ្វើវិចារណកម្មនោះទេ។ ទន្ទឹមគ្នានេះ សិល្បករសិល្បការិនីនៅក្រៅប្រព័ន្ធ ក៏ត្រូវបានរដ្ឋាភិបាលយកចិត្តទុកដាក់ផ្តល់អាទិភាពឱ្យទទួលបានការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ក្នុងពេលតែមួយជាមួយថ្នាក់ដឹកនាំនិងមន្ត្រីរាជការរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈផងដែរ កាលពីឆ្នាំ២០២១កន្លងទៅ។

ទន្ទឹមនឹងការងារអភិរក្សវប្បធម៌ដែលយើងបានអនុវត្តជាច្រើនកន្លងមកចាប់តាំងពីក្រោយការផ្តួលរំលំរបបខ្មែរក្រហម រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវចក្ខុវិស័យដ៏វែងឆ្ងាយនិងប្រកបដោយមហិច្ឆតាមួយក្នុងការប្រែក្លាយសក្តានុពលវប្បធម៌ជាតិដែលមានស្រាប់ ប្រកួមជាមួយនឹងយុទ្ធសាស្ត្រអភិវឌ្ឍឧស្សាហកម្មវប្បធម៌និងច្នៃប្រឌិតថ្មីៗ ដើម្បីលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព បរិយាប័ន្ន និងពិពិធកម្ម ស្របទៅតាមបរិបទនៃការអភិវឌ្ឍវប្បធម៌នៅក្នុងតំបន់និងពិភពលោក។ ជាក់ស្តែង សម្រាប់និន្នាការនៅក្នុងតំបន់ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថា "អាស៊ាន" បាននិងកំពុងរៀបចំក្របខណ្ឌយុទ្ធសាស្ត្ររួមមួយ ដោយប្រើប្រាស់យន្តការសហគមន៍សង្គមវប្បធម៌និងសហគមន៍សេដ្ឋកិច្ចអាស៊ាន ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចច្នៃប្រឌិតរបស់តំបន់ឱ្យមានវិបុលភាពដូចបណ្តាប្រទេសអភិវឌ្ឍន៍នៅលោកខាងលិច ស្របពេលដែលអង្គការសហប្រជាជាតិបានប្រកាសយកឆ្នាំ២០២១ ធ្វើជា **"ឆ្នាំអន្តរជាតិនៃសេដ្ឋកិច្ចច្នៃប្រឌិតសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព"** (International Year of Creative Economy for Sustainable Development)។ ទន្ទឹមគ្នានេះដែរ រដ្ឋមន្ត្រីវប្បធម៌នៃបណ្តាប្រទេសដែលមានសេដ្ឋកិច្ចធំជាងគេបំផុតក្នុងលោកទាំង២០ (G20) ក៏បានឯកភាពគ្នាជាប្រវត្តិសាស្ត្រលើកដំបូងកាលពីឆ្នាំ២០២១កន្លងទៅ ដាក់ចេញនូវ **"សេចក្តីថ្លែងការណ៍របស់ប្រទេស G20 ស្តីពីវប្បធម៌"** (G20 Declaration on Culture) ដោយសង្កត់ធ្ងន់លើសារៈសំខាន់របស់វប្បធម៌នៅក្នុងតួនាទីស្តារសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាពបន្ទាប់ពីវិបត្តិកូវីដ-១៩ តាមរយៈអាទិភាពគន្លឹះចំនួន៥រួមមាន កិច្ចការពារ

បេតិកភណ្ឌវប្បធម៌, វប្បធម៌និងការប្រែប្រួលអាកាសធាតុ, វប្បធម៌និងការអប់រំ, ឧស្សាហកម្មវប្បធម៌និងច្នៃប្រឌិត, និងវប្បធម៌ក្នុងបរិវត្តកម្មឌីជីថល។ នៅក្នុងន័យនេះ គ្រប់ប្រទេសទាំងអស់ រួមទាំងប្រទេសកម្ពុជាផងដែរ គឺបាននិងកំពុងបង្កើនសកម្មភាពនិងការវិនិយោគទៅក្នុងវិស័យវប្បធម៌កាន់តែច្រើនឡើង ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួន ឱ្យស្របទៅតាមបរិបទថ្មីៗនាពេលបច្ចុប្បន្ន។

ទោះបីរងផលប៉ះពាល់ពីវិបត្តិនៃជំងឺកូវីដ-១៩យ៉ាងណាក្តី សិល្បៈវប្បធម៌កម្ពុជានៅតែមានភាពធន់ ប្រៀបបានទៅនឹងកងទ័ពជួរក្រោយ ដែលតែងតែបង្ហាញសកម្មភាពជាប្រចាំក្នុងការជួយជំរុញលើកទឹកចិត្ត ដល់កងទ័ពជួរមុខ ក្នុងការប្រយុទ្ធប្រឆាំងតតាំងជាមួយមេរោគជំកាចសាហាវមួយនេះ។ តាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា និងភាពជាដៃគូល្អរវាងរដ្ឋនិងឯកជន ធ្វើឱ្យឧស្សាហកម្មភាពយន្ត ចម្រៀង និងតន្ត្រីកម្ពុជា មានការប្រែប្រួលមុខមាត់កាន់តែប្រសើរឡើងគួរជាទីមោទនៈទាំងនៅក្នុងប្រទេសនិងនៅលើឆាកអន្តរជាតិ។ ក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ ឧស្សាហកម្មចម្រៀងនិងភាពយន្តខ្មែរ ពិសេសភាពយន្តសម្រាប់ចាក់បញ្ចាំងតាមកញ្ចក់ទូរទស្សន៍ គឺត្រូវបានផលិតជាស្នាដៃនិពន្ធថ្មីបានកាន់តែច្រើន ហើយគុណភាពក៏កាន់តែល្អប្រសើរស្របទៅតាមតម្រូវការសង្គមបច្ចុប្បន្ន។ ខ្ញុំសូមយកឱកាសនេះ សម្តែងនូវសេចក្តីសប្បាយរីករាយនិងសូមវាយតម្លៃខ្ពស់ចំពោះទឹកចិត្តនិងឆន្ទៈរបស់បងប្អូនជនរួមជាតិនៅក្នុងវិស័យឯកជនទាំងអស់ដែលបានខិតខំនិពន្ធនិងបង្កើតស្នាដៃសិល្បៈថ្មីៗដែលមានគុណភាពស្របតាមច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល ដោយក្នុងនោះក៏មានការចូលរួមជួយលើកកម្ពស់សិល្បៈវប្បធម៌បុរាណខ្មែរនៅក្នុងស្នាដៃនិពន្ធថ្មីរបស់ខ្លួនផងដែរ។ ឧស្សាហកម្មភាពយន្ត ចម្រៀង និងតន្ត្រី គឺជាឧស្សាហកម្មច្នៃប្រឌិតនៅក្នុងវិស័យវប្បធម៌ដែលមានសក្តានុពលមិនចេះរីងស្ងួត ដែលតួអង្គក្នុងវិស័យឯកជនទាំងអស់ត្រូវខិតខំទាញយកឱកាសទាំងនេះឱ្យបានជាអតិបរមា ជាពិសេសនៅពេលដែលរាជរដ្ឋាភិបាលបានបើកឱ្យដំណើរការឡើងវិញនូវសកម្មភាពសង្គមនិងសេដ្ឋកិច្ច រួមទាំង សារមន្ទីរ រោងភាពយន្ត រោងសម្តែងសិល្បៈ ក៏ដូចជាការរៀបចំពិធីអាពាហ៍ពិពាហ៍និងពិធីបុណ្យប្រពៃណីនានាជាដើម។ ការដាក់ចេញនូវនីតិវិធីប្រតិបត្តិស្តង់ដារ(SOP)សម្រាប់សកម្មភាពសិល្បៈវប្បធម៌ បូករួមនឹងភាពជោគជ័យនៃយុទ្ធនាការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ខ្ញុំពិតជាមានសុទិដ្ឋិនិយមថាឧស្សាហកម្មវប្បធម៌កម្ពុជានឹងមានសន្ទុះងើបឡើងវិញឆាប់ និងចូលរួមស្តារជីវភាពរបស់ប្រជាពលរដ្ឋ និងសេដ្ឋកិច្ចកម្ពុជា ទាំងនៅក្នុងអំឡុងនិងក្រោយពេលវិបត្តិកូវីដ-១៩។

*បងប្អូនជនរួមជាតិទាំងអស់ជាទីស្រឡាញ់រាប់អាន!*

គិតមកដល់ឆ្នាំ២០២២នេះ គឺយើងបានឈានផុតពាក់កណ្តាលអាណត្តិរបស់រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា ហើយយើងក៏បានឈានចូលដល់ដំណាក់កាល១០ឆ្នាំចុងក្រោយនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព២០១៦-២០៣០ របស់អង្គការសហប្រជាជាតិផងដែរ។ ក្នុងរយៈពេលជាងពាក់កណ្តាលអាណត្តិកន្លងទៅនេះ រាជរដ្ឋាភិបាលកម្ពុជាដែលមានក្រសួងវប្បធម៌និងវិចិត្រសិល្បៈជាសេនាធិការ បានបន្តខិតខំប្រឹងប្រែងអនុវត្តនិងសហការអនុវត្តការងារគ្រប់មុខព្រួញទាំងអស់នៃយុទ្ធសាស្ត្រ ទាំងការងារអភិរក្ស ការងារលើកស្ទួយតម្លៃ និងការងារអភិវឌ្ឍវប្បធម៌ជាតិ ស្របតាមចក្ខុវិស័យ **"អភិរក្សនិងអភិវឌ្ឍវប្បធម៌ជាតិ ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចសង្គម"** ដែលបានកំណត់នៅក្នុងគោលនយោបាយជាតិស្តីពីវិស័យវប្បធម៌ និង

អនុលោមទៅតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។ ក្នុងនោះ សូចនាករនិងអាទិភាពគន្លឹះសំខាន់ៗសម្រាប់អនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣, គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា២០១៦-២០៣០, គោលនយោបាយជាតិស្តីពីវិស័យវប្បធម៌ និងឯកសារយុទ្ធសាស្ត្រក្នុងក្របខណ្ឌការងារអន្តរវិស័យទាំងអស់ គឺសម្រេចទៅបានតាមការគ្រោងទុក ដោយធានាបាននូវការរួមចំណែកដល់ការអភិវឌ្ឍប្រកបដោយចីរភាព បរិយាប័ន្ន និងការធ្វើពិពិធកម្មសេដ្ឋកិច្ច។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងដោយឈរលើស្មារតីសហការ និងទទួលខុសត្រូវខ្ពស់របស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំនិងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ព្រមទាំងដៃគូជាតិនិងអន្តរជាតិទាំងអស់ ដែលបានចូលរួមយ៉ាងសកម្មក្នុងបុព្វហេតុអភិរក្ស លើកស្ទួយតម្លៃ និងអភិវឌ្ឍវប្បធម៌ជាតិ ជាពិសេសនៅក្នុងកាលៈទេសៈដ៏លំបាកនៃការបើទខ្ទប់ភូមិសាស្ត្រដើម្បីទប់ស្កាត់ការរីករាលដាលឆ្លងជំងឺកូវីដ-១៩ កាលពីឆ្នាំ២០២១កន្លងទៅ។ ទន្ទឹមគ្នានេះ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះដៃគូអភិវឌ្ឍន៍ និងសប្បុរសជននានា ដែលបានចូលរួមសហការ និងឧបត្ថម្ភគាំទ្រដល់ការងារវប្បធម៌កន្លងមក ហើយខ្ញុំក៏សង្ឃឹមថាភាគីពាក់ព័ន្ធទាំងអស់នឹងបន្តចូលរួមជួយជ្រោមជ្រែង ផ្តល់កិច្ចសហការ និងឧបត្ថម្ភគាំទ្រដល់ការងារវប្បធម៌ថ្មីៗបន្ថែមទៀត ដើម្បីជ្រោងសិល្បៈវប្បធម៌ខ្មែរឱ្យកាន់តែមានភាពខ្ពស់ត្រដែត លេចធ្លោ និងត្រចះត្រចង់បន្ថែមទៀតទាំងនៅលើឆាកជាតិ និងអន្តរជាតិ ស្របតាមទិសស្លោក **"កម្ពុជា៖ ព្រះរាជាណាចក្រនៃវប្បធម៌"**។

មុននឹងបញ្ចប់ ខ្ញុំសូមយកឱកាសទិវាវប្បធម៌ជាតិ លើកទី២៤នេះ ដើម្បីរំលឹកដល់គុណូបការៈព្រះមហាក្សត្រខ្មែរគ្រប់ជំនាន់ ដែលព្រះអង្គបានលះបង់អស់ពីព្រះកាយពល ព្រះហឫទ័យ និងព្រះបញ្ញាញាណ រួមជាមួយនឹងបុព្វបុរសខ្មែរគ្រប់រូប ដែលបានបូជាលះបង់កម្លាំងកាយចិត្តគ្រប់បែបយ៉ាងក្នុងការបង្កើត ថែរក្សា និងការពារសម្បត្តិវប្បធម៌ដ៏សម្បូរបែប និងមិនអាចកាត់ថ្លៃបាន ហើយដែលបានបន្សល់ទុកមករហូតដល់បច្ចុប្បន្ន។ ជាមួយគ្នានេះដែរ ខ្ញុំក៏សូមឧទ្ទិសសមិទ្ធផលការងារវប្បធម៌ដែលរាជរដ្ឋាភិបាលកម្ពុជាសម្រេចបានជាបន្តបន្ទាប់ ព្រមទាំងកម្មវិធីអបអរសាទរទិវាវប្បធម៌ជាតិ ក្នុងឆ្នាំ២០២២នេះ ចំពោះដួងព្រលឹងបុព្វបុរសខ្មែរ ដែលបានលាចាកលោកកន្លងទៅ និងសូមឱ្យវិញ្ញាណខន្ធលោកទាំងអស់បានទៅកាន់ទីបរមសុខ។ ខ្ញុំក៏សូមសម្តែងការកោតសរសើរ និងលើកទឹកចិត្តចំពោះមរតកមនុស្សរស់ និងអ្នកជំនាញផ្នែកសិល្បៈបុរាណខ្មែរទាំងអស់ ដែលកំពុងបន្តសកម្មភាពដ៏មានអត្ថន័យនិងមានតម្លៃដ៏ខ្ពង់ខ្ពស់នេះផងដែរ។

ជាចុងក្រោយ ខ្ញុំសូមជូនពរបងប្អូនជនរួមជាតិទាំងអស់ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមឱ្យមនសិការស្នេហាជាតិនិងស្មារតីស្រឡាញ់សិល្បៈវប្បធម៌ រីកដុះដាលក្នុងស្មារតីនិងសកម្មភាពរបស់ជនជាតិខ្មែរគ្រប់ៗរូបជានិច្ចនិរន្តរ៍ ជាពិសេសក្នុងចំណោមយុវជនខ្មែរ ដែលត្រូវបន្តវេនអភិរក្ស លើកស្ទួយតម្លៃ និងអភិវឌ្ឍវប្បធម៌ជាតិ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។

ថ្ងៃព្រហ [illegible] ខែ[illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែកុម្ភៈ ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**